សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ២៧ មេសា ២០២០

លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ២៧ មេសា ២០២០

## *របាយការណ៍តាមដានស្ថានភាពរយៈពេល ៦ សប្តាហ៍ចុងក្រោយ រៀបចំដោយក្រុមពេទ្យ និងក្រុមសុខាភិបាលថ្នាក់ជាតិ*

## *សាលាក្រុង* Revere *បញ្ចេញទិន្នន័យ និងការសិក្សាសំខាន់ៗ*

ថ្ងៃទី ២៧ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 សរុបចំនួន ១០៦៤ ករណីនៅក្នុងក្រុង Revere។ ក្រុមឃ្លាំមើល និងតាមដានពីស្ថានភាពជំងឺ បានធ្វើការទាក់ទងតាមទូរស័ព្ទទៅកាន់មនុស្សចំនួន ៩៤៦ នាក់បន្ថែមទៀត ដែលធ្លាប់មានទំនាក់ទំនងជាមួយអ្នកឆ្លងខាងលើ ដើម្បីប្រាប់ពួកគេឲ្យមានការយកចិត្តខ្ពស់លើការរស់នៅដាច់ដោយឡែក និងប្រុងប្រយ័ត្នក្នុងការទាក់ទងជាមួយអ្នកដទៃ។ ក្រុមការងារនៅតែបន្តដំណើរការទាញយកទិន្នន័យ និងព័ត៌មានផ្សេងទៀត ដើម្បីផ្តល់ជូនទៅក្រុមសុខភាពសាធារណៈ។

"ការងារផ្នែកទំនាក់ទំនង និងតាមដានរកអ្នកដែលធ្លាប់ប៉ះពាល់ជាមួយអ្នកឆ្លង COVID-19 នេះ គឺធ្វើឡើងដើម្បីសម្រេចបំណងចំនួន ២ ដូចជា គ្រប់គ្រង់ស្ថានភាពនៃការរីករាលដាលក្នុងតំបន់ និងការបង្កើនគ្រឹះសុវត្ថិភាព និងគ្រង់គ្រងលើសុវត្ថិភាពនៅពេលដែលយើងអាចបើកក្រុង និងអគារនានាឡើងវិញ។ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រុមគិលានុបដ្ឋាយិកា ពួកយើងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ "។ នេះសម្តីរបស់លោក Nathalee Kong ប្រធានក្រុមប្រឹក្សាសុខាភិបាលប្រចាំក្រុង Revere។

កម្មវិធីតាមដាននេះ បានធ្វើឡើងតាំងពីថ្ងៃទី ១៩ មិនា និងបានរៀបចំឡើងដោយក្រុមគិលានុបដ្ឋាយិកាសាធារណៈប្រចាំក្រុង។ ក្រុមនេះមានសមាជិកចំនួន ១២ នាក់ជានិស្សិតផ្នែកគិលានុបដ្ឋាក និងអ្នកស្ម័គ្រចិត្ត ៣ នាក់ដែលជាប្រជាជនរបស់ Revere រួមជាមួយអ្នកឯកទេសរៀបចំទិន្នន័យម្នាក់។ ក្រុមនេះ បានប្រើ software ដែលទិញពី Denver-based CiviCore។ តាមរយៈការទទួលទូរសព្ទ គិលានុបដ្ឋាយិកាទាំងនេះ កំពុងប្រមូលព័ត៌មានពីបុគ្គលម្នាក់ៗ ដើម្បីកំណត់អត្តសញ្ញាណនៃមេរោគ COVID-19។ ក្រៅពីបានស្រង់មតិហើយនោះ ក្រុមគិលានុបដ្ឋាយិកាក៏បានណែនាំបន្ថែមពីវិធានរក្សាគម្លាត និងលើកទឹកចិត្តពួកគេឲ្យរស់នៅដោយឡែក រួមជាមួយការផ្តល់នូវចម្លើយផ្សេងៗទាក់ទងនឹងអាការៈរោគ កម្មវិធី

ដឹកជញ្ជូនអាហារ ការធ្វើតេស្ត និងសេវាជួយថៃទាំផ្ទះផងដែរ។ ក្រុមអ្នកតាមដាននេះ បានបញ្ជូនមនុស្សចំនួន ១១៥ នាក់ សម្រាប់ផ្តល់ជំនួយ តាមរយៈប្រព័ន្ធអ្នកស្ម័គ្រចិត្តរបស់ក្រុង។

ជាលទ្ធផល សាលាក្រុងបានអនុវត្តសេចក្តីណែនាំថ្មីយ៉ាងឆាប់រហ័ស និងផ្តល់ការណែនាំថ្មីៗដល់អ្នករស់នៅ និងម្ចាស់អាជីវកម្ម។ ជាឧទាហរណ៍ បន្ទាប់ពីរកឃើញករណីជាក្រុមៗ ដែលជាប់ទាក់ទង នឹងហាងលក់គ្រឿងទេសមួយនៅក្នុងទីក្រុង មន្ត្រីសុខាភិបាលសាធារណៈ បានសម្របសម្រួលចុះត្រួតពិនិត្យ និងតម្រូវឲ្យហាងកាត់បន្ថយចំនួនមនុស្សដែលត្រូវចូលក្នុងពេលម្តងៗ។

សាលាក្រុង ក៏បានចាប់ផ្តើមតាមដានស្ថានភាពអ្នកដែលបានជាសះស្បើយពីមេរោគផងដែរ។ ជាការប៉ាន់ស្មានទៅអំឡុងពេលច្រើនសប្តាហ៍ខាងមុខទៀត ក៏ដូចជាអនុភាពនៃការរឹតបន្តឹង Revere នឹងពឹងផ្អែកលើប្រព័ន្ធតាមដាននេះ និងការប្រើប្រាស់ទិន្នន័យដែលពាក់ព័ន្ធពីរដ្ឋ ដើម្បីអាចកំណត់បាននូវអ្វីដែលកំពុងដំណើរការ។ សាលាក្រុងនឹងនៅតែផ្តល់ការយកចិត្តទុកដាក់ខ្ពស់ទៅដល់អ្នកឆ្លង និងអ្នកធ្លាប់មានទំនាក់ទំនងជាមួយអ្នកឆ្លងទាំងអស់ ដើម្បីកាត់បន្ថយការរីករាលដាលបន្ថែមទៀត។

## របាយការណ៍សំខាន់ៗ ប្រចាំក្រុម Revere៖

- សាលាក្រុង Revere បានទទួលដំណឹងពីនាយកដ្ឋានសុខភាពសាធារណៈថា  ចំនួនអ្នកឆ្លងមានសរុប ១០៦៤ ករណី ដោយមានអ្នកស្លាប់ ៣៥នាក់ និងជាសះស្បើយ ២៥០ នាក់។
- ចំនួនអ្នកឆ្លងទាំង ២ ភេទ មានចំនួនប្រហាក់ប្រហែលគ្នា
- ប្រមាណ ២៨% នៃចំនួនអ្នកឆ្លង មានអាយុចាប់ពី ៦០ ឆ្នាំឡើងឡើង ខណៈ ៣៧% មានអាយុចន្លោះ៣ ៤០ ទៅ ៥៩ និង ៣១% មានអាយុចន្លោះពី ២០ ទៅ ៣៩ឆ្នាំ និង ៤% ជាក្មេងៗអាយុក្រោម ១៩ឆ្នាំ។
- ក្នុងចំណោមអ្នកដែលស្លាប់ចំនួន ៣៥ នាក់នោះ មាន ២៣ នាក់មានអាយុចាប់ពី ៨០ ឆ្នាំឡើង ៨ នាក់អាយុចាប់ពី ៦០ ដល់ ៧៩ ឆ្នាំ ៣ នាក់មានអាយុចន្លោះ ៤០ ទៅ ៥៩ និង ១ មានអាយុក្រោម ៤០ ឆ្នាំ។
- មនុស្សចំនួន ១៨១ នាក់ត្រូវបានរកឃើញថាមានជំងឺ ក្រោយការតាមដានថាធ្លាប់ប៉ះពាល់ ឬមានទំនាក់ទំនងជាមួយអ្នកដែលធ្លាប់ឆ្លងហើយ។
- សាលាក្រុងក៏បានប្រមូលទិន្នន័យអំពីអ្នកឆ្លង គិតតាមពូជសាសន៍ និងសញ្ជាតិផងដែរ។ ៤២% នៃករណីឆ្លងទាំងអស់ គឺបានមកពី MAVEN។ ការវិភាគនៃសំណុំរងមានដូចជា ៤៨% ជាជនជាតិស្បែកស ៤០% ជាក្រុមអាមេរិកឡាទីន ៥.៤% ជាក្រុមមជ្ឈឹមបូព៌ា ៣.៩% ជាជនជាតិអាស៊ី និង ៣.២% ជាជនជាតិស្បែកខ្មៅ៕